ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តស្ទឹងត្រែង

សំណុំរឿងលេខ៖ ០៤៤ រណ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៩
សញ្ញាណនៃរឿងក្តី៖ សុំបញ្ឈប់ការរួមរស់ជាអនីតិសង្វាស
ទាញហេតុផលដោយផ្ទាល់មាត់បញ្ចប់ ថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ ២០១៩
សាលក្រមលេខ៖ ០៦ "ឃ" ចុះថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តស្ទឹងត្រែង**

បានធ្វើការទាញហេតុផលនៅថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ ២០១៩ វេលាម៉ោង២ និង៣០ នាទីរសៀល និងប្រកាសសាលក្រមនៅថ្ងៃ ខែ ឆ្នាំដដែល វេលាម៉ោង ៤ និង ៣០ នាទីរសៀល ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តស្ទឹងត្រែង

**ដើមចោទ៖** ឈ្មោះ [redacted] ធាវី ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ [redacted]។

**អ្នកតំណាងដោយអាណត្តិ** (ដើមចោទ) ៖ លោកមេធាវី [redacted]។

**ចុងចម្លើយ៖** ឈ្មោះ [redacted] ម៉េងសាយ ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នកំពុងជាប់ឃុំខ្លួននៅពន្ធនាគារ។

**អ្នកតំណាងដោយអាណត្តិ** (ចុងចម្លើយ) ៖ គ្មាន។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

**១-សាលក្រមដែលទាមទារដោយដើមចោទ៖**

-ប្តឹងសុំបំបែកលំនៅជាអនីតិសង្វាស
-ប្តឹងសុំសិទ្ធគ្រប់គ្រងកូនចំនួន០៤នាក់
-ប្តឹងសុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែក

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

**២-១**-កាលពីអំឡុងឆ្នាំ២០០១ ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ម៉េងសាយ ដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ។ ដើមចោទអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយនឹងចុងចម្លើយតទៅទៀត ដោយហេតុថាការរួមរស់ជាមួយគ្នាមិនចុះសម្រុង ព្រោះចុងចម្លើយតែងតែ



Scanned with CamScanner

-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែក តែខ្លួនសុំស្នើឲ្យតុលាការបែងចែកដោយចំណែករបស់ដើមចោទ សុំឲ្យមានឈ្មោះកូនច្បង [redacted] ម៉េងទី អាយុ ១៨ឆ្នាំ មាននៅក្នុងនោះផង ដើម្បីជាដំណាងរបស់ប្អូនៗទាំងបីដែលមិនទាន់មានសិទ្ធិ ដើម្បីជាទ្រព្យឲ្យកូនៗទៅថ្ងៃមុខ ព្រោះខ្លួនមិនបានបង់អាហារការពូកិច្ច ដល់កូនៗទេ។

**គ-ការអះអាងតបរបស់ដើមចោទ**

ដើមចោទយល់ព្រមតាមការស្នើសុំរបស់ ចុងចម្លើយដោយឯកភាពលើដី២ប្លង់ខាងលើគឺសុំឲ្យតុលាការដាក់ឈ្មោះកូនប្រុសរបស់ខ្លួន [redacted] ម៉េងទី និងឈ្មោះខ្លួនលើប្លង់តាំងពីរនេះ។

**២-៣-ចំណុចគ្មានវិវាទ៖**

ភាគីបានព្រមព្រៀងគ្នាគ្រប់ចំណុចដូចការថ្លែងខាងលើ៖

-ដើមចោទសុំបំបែកលំនៅជាអនីតិសង្វាស ជាមួយចុងចម្លើយ

-ព្រមព្រៀងប្រគល់សិទ្ធិឲ្យដើមចោទគ្រប់គ្រងកូនចំនួន០៤នាក់

-ព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែក តែក្នុងចំណែករបស់ដើមចោទ សុំឲ្យមានឈ្មោះកូនច្បង [redacted] ម៉េងទី អាយុ ១៨ឆ្នាំ នៅក្នុងប្លង់។

-មិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូន។

**២-៤-ចំណុចវិវាទ៖** គ្មាន

**៣-ប្រាក់ពន្ធដៀនៗ** ៖ ជាបន្ទុករបស់ដើមចោទ។

## សំអាងហេតុ

តាមលទ្ធផលពិនិត្យភស្តុតាងក្នុងដំណាក់កាលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។

## យល់ឃើញថា

១-ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍តាំងពីអំឡុងឆ្នាំ ២០០១ មកម្លេះ តែពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឡើយ ចំណុចនេះបញ្ជាក់បានថារវាងដើមចោទ និងចុងចម្លើយពុំមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណីឡើយ គឺរវាងដើមចោទនិងចុងចម្លើយរស់នៅជាមួយគ្នាជាអនីតិសង្វាស ដែលចំណុចនេះតុលាការពិចារណាឃើញថា ភាគីនីមួយៗមានសិទ្ធិសេរីភាពពេញលេញក្នុងការរស់នៅ ការរៀបអាពាហ៍ពិពាហ៍ និងការចាត់ចែងដោយសេរី ស្របទៅតាមច្បាប់សម្រាប់រូបវន្តបុគ្គលម្នាក់ៗ ដោយគ្មានភាគីណាមួយអាចរាំងចំពោះសិទ្ធិបុគ្គល ដែលពុំមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះឡើយ ។

២-ដើមចោទបានដាក់ពាក្យបណ្តឹងមកតុលាការ ដោយទាមទារសុំឲ្យតុលាការចេញសាលក្រមឲ្យខ្លួនបានឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយ ដោយលើកមូលហេតុថាការរួមរស់នៅជាមួយគ្នាកន្លងមកតែងតែមានទំនាស់នឹងគ្នាជាញឹកញាប់ មិនយល់ចិត្តគ្នា ចេះតែមានភាពរកាំរកូស និងពុំសូវមានសេចក្តីសុខក្នុងរង្វង់គ្រួសារទេ មូលហេតុទាំងអស់នេះហើយ ទើបធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាពីចុងចម្លើយ ចំណែកឯចុងចម្លើយក៏ទទួលស្គាល់អង្គហេតុដូចការអះអាងរបស់ដើមចោទដែរ ហើយខ្លួនសុំឯកភាពតាមការទាមទារឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទ។ ចំណុចនេះតុលាការពិចារណាឃើញថាការទាមទារ និងលើកមូលហេតុរបស់ដើមចោទមានមូលដ្ឋានសមរម្យ ដែលអាចឲ្យតុលាការចេញសេចក្តីសម្រេចបំបែកការរួមរស់ជាអនីតិសង្វាសរវាងដើមចោទ និងចុងចម្លើយបានទៅតាមការព្រមព្រៀងរបស់គូភាគីបាន ។

២-ឲ្យដើមចោទឈ្មោះ [redacted] ធារី ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម តាមមាត្រា ៩៥០ ចំណុចទី១ នៃក្រមរដ្ឋប្បវេណី។

៣-កំណត់យកឈ្មោះ [redacted] ធារី ជាអ្នកមានអំណាចមេបាលើកូនចំនួន០៤នាក់ ដោយកូនទី១ឈ្មោះ [redacted] ម៉េងទី ភេទ ប្រុស អាយុ១៨ឆ្នាំ កូនទី២ឈ្មោះ [redacted] ម៉េងលី ភេទប្រុស អាយុ១៧ឆ្នាំ កូនទី៣ឈ្មោះ [redacted] ធីណា ភេទស្រី អាយុ១៤ឆ្នាំ និងកូនទី៤ឈ្មោះ [redacted] ជានី ភេទស្រី អាយុ១០ឆ្នាំ។ ភាគីដែលពុំមានអំណាចមេបាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ ភាគីដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមមាត្រា ១០៣៧ និង១០៤០ នៃក្រមរដ្ឋប្បវេណី។

៤-ប្រគល់ដីទំហំ ៤៥.៤៥៥ ម៉ែត្រការ៉េ ដែលស្ថិតនៅភូមិអូរឫស្សីកណ្ដាល ឃុំអូរឫស្សីកណ្ដាល ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:១៩០២០៥០១-១៧៨៥ ចុះថ្ងៃ ទី២០ ខែមករា ឆ្នាំ២០១៣ និងដីមួយកន្លែងទៀតទំហំ ៤៩.៨៩៤ ម៉ែត្រការ៉េ ដែលស្ថិតនៅភូមិអូរឫស្សីកណ្ដាល ឃុំអូរឫស្សីកណ្ដាល ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៥០១-០១០២ ចុះថ្ងៃ ទី២០ ខែមករា ឆ្នាំ២០១៣ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តស្ទឹងត្រែង ឲ្យដើមចោទឈ្មោះ [redacted] ធារី និង ឈ្មោះ [redacted] ម៉េងទី អាយុ ១៨ឆ្នាំ។

៥-ប្រគល់ដីទំហំ ៤៨.០២៤ ម៉ែត្រការ៉េ ដែលស្ថិតនៅភូមិអូរឫស្សីកណ្ដាល ឃុំអូរឫស្សីកណ្ដាល ស្រុកសៀមបូក ខេត្តស្ទឹងត្រែង មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៩០២០៥០១-០១០២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៣ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តស្ទឹងត្រែង ឲ្យចុងចម្លើយឈ្មោះ [redacted] ម៉េងសាយ ។

៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះធ្វើការទាញហេតុផលផ្ទាល់មាត់ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង២ និង៣០នាទីរសៀល និងធ្វើការប្រកាសសាលក្រមនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ៤ និង ៣០នាទីរសៀល ចំពោះមុខភាគីដើមចោទឈ្មោះ [redacted] ធារី និងមេធាវី ចាច់ ពេជ្រ និងចុងចម្លើយឈ្មោះ [redacted] ម៉េងសាយ។

**រក្សាសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។**

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ និង ឯកភាព**

**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ២កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ស្ទឹងត្រែង, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១៩

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner